ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ០១៨......សហវ.[illegible]

# សេចក្ដីសម្រេច
## ស្ដីពី
## ការបង្កើតក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ២០១៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្ដីពីការតែងតាំង និងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧១៩/១០២៤ ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០១៩ ស្ដីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្ដីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
mef.gov.kh
t.me/mefcambodia
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666
info@mef.gov.kh
mef.cabinet@mef.gov.kh

- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញសារាចរណ៍រាជរដ្ឋាភិបាលលេខ ០៩ សរ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ស្ដីពីវិធាននិងនីតិវិធីនៃការរៀបចំការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.–**

ត្រូវបានបង្កើតក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ ដែលហៅកាត់ថា **ក.ហ.ស.** នៃ **អ.ល.សា** ដែលមានសមាសភាពដូចខាងក្រោម ÷

| | | |
|---|---|---|
| ១. ឯកឧត្តម **ឈឹម សារ៉េត** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | ប្រធាន |
| ២. ឯកឧត្តម **ហួត ចន្ថា** | អគ្គនាយករងនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | អនុប្រធានប្រចាំការ |
| ៣. ឯកឧត្តម **ម៉ាន់ គិរម្យ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | អនុប្រធាន |
| ៤. ឯកឧត្តម **សេង ស្រេង** | អគ្គនាយករងនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | អនុប្រធាន |
| ៥. លោកស្រី **ឌីច សុចិន្តា** | ប្រធាននាយកដ្ឋានគ្រប់គ្រងលទ្ធកម្មទំនិញ | សមាជិក |
| ៦. លោក **សួន សុភាព** | អនុប្រធាននាយកដ្ឋានគ្រប់គ្រងលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិ | សមាជិក |
| ៧. លោក **ឈុន ពៅ** | ប្រធានការិយាល័យលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិទី៤ | សមាជិក |
| ៨. លោក **ទេព មុត្រា** | ប្រធានការិយាល័យអធិការកិច្ចនិងដោះស្រាយវិវាទលទ្ធកម្ម | សមាជិក |
| ៩. លោក **ហ៊ុន បូរិន** | ប្រធានការិយាល័យត្រួតពិនិត្យលទ្ធកម្មអង្គភាពស្វយ័ត | សមាជិក |
| ១០. លោក **ខែត គីមហាយ** | ប្រធានការិយាល័យបច្ចេកវិទ្យាព័ត៌មាន | សមាជិក |
| ១១. លោកស្រី **អ៊ុង សុគន្ធ** | អនុប្រធានការិយាល័យលទ្ធកម្មសំណង់និងសេវាទី១ | សមាជិក |
| ១២. លោក **សាយ ទិទ្ធិកា** | អនុប្រធានការិយាល័យលទ្ធកម្មរដ្ឋបាលថ្នាក់ក្រោមជាតិទី២ | សមាជិក |
| ១៣. លោក **ឆាយ៉ា ពិសិដ្ឋ** | អនុប្រធានការិយាល័យលទ្ធកម្មទំនិញទី១ | សមាជិក |
| ១៤. លោក **ជោគ មុនីភក្តី** | អនុប្រធានការិយាល័យបច្ចេកវិទ្យាព័ត៌មាន | សមាជិក |
| ១៥. លោកស្រី **ឈឹម ទិដ្ឋជា** | អនុប្រធានការិយាល័យលទ្ធកម្មសំណង់និងសេវាទី៣ | សមាជិក |
| ១៦. លោក **តែ យូនា** | អនុប្រធានការិយាល័យផែនការនិងស្ថិតិ | សមាជិក |
| ១៧. លោក **ឆាយ ទិសាល** | អនុប្រធានការិយាល័យត្រួតពិនិត្យលទ្ធកម្មរដ្ឋបាលរាជធានី ខេត្ត | សមាជិក |
| ១៨. លោកស្រី **គីម សុវណ្ណាទី** | មន្ត្រីការិយាល័យលទ្ធកម្មទំនិញទី២ | សមាជិក |
| ១៩. លោក **ជុំ តត្រា** | អនុប្រធានការិយាល័យគ្រប់គ្រងកិច្ចសន្យា | មន្ត្រីសម្របសម្រួល |
| ២០. លោក **លីម ចិន្តពិសិដ្ឋ** | ប្រធានការិយាល័យផែនការ និងស្ថិតិ | លេខាធិការ ។ |

**ប្រការ២ .-**

ប្រធាន **គ.ហ.ស.** ដូចមានចែងក្នុងប្រការ១ នៃសេចក្ដីសម្រេចនេះ ត្រូវកំណត់កិច្ចដំណើរការ **គ.ហ.ស.** នៃ **អ.ល.សា** ដើម្បីចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

**ប្រការ៣ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្ដីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤ .-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ២ កើត ខែ មាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ មករា ឆ្នាំ២០២៣

**ជ.នាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- ដូចប្រការ៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ